# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១**
**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូនាពេលនេះ!**

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងសកម្ម ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ដោយសារតែមានការចូលរួមយ៉ាងសកម្មពីឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវលទ្ធផលជាផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតចំពោះ សមាជិក សមាជិកានៃអង្គពិធីទាំងមូល។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះ ដោយខ្ញុំសូមរំឭកអំពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការរៀបចំដំណើរឆ្លងកាត់ពីអន្តរកាលឆ្ពោះទៅកាន់ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីធ្វើឱ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្តេជ្ញាបញ្ចប់ជំងឺអេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០២៥ខាងមុខ ដែលរួមមានដូចតទៅ ៖

១) យើងទាំងអស់គ្នា ពិតជាបានខិតខំអនុវត្តផែនការសកម្មភាពរយៈពេល៦ខែចុងឆ្នាំ២០២១ ទៅតាមក្រសួង ស្ថាប័នជាតិ ដៃគូអន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទោះជាស្ថិតនៅក្រោមការគំរាមកំហែងជាបន្តពីជំងឺកូវីដ-១៩ក៏ដោយ។

២) យើងត្រូវជំរុញធ្វើឱ្យសម្រេចបាននូវគោលដៅ៩៥ ទី១ តាមរយៈការលុបបំបាត់នូវវិសមភាពចំពោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ ធានាធ្វើយ៉ាងណាឱ្យពួកគេអាចមកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ សេវាព្យាបាលថែទាំ ដោយសេរី និងទាន់ពេលវេលា។

៣) យើងត្រូវរៀបចំរចនាសម្ព័ន្ធ ផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ក្នុងការពង្រឹងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងរាជធានី ខេត្តទាំង៤ ធានាសម្រេចឱ្យបាននូវគំនិតផ្តួចផ្តើមទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

៤) អង្គប្រជុំសូមលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញ និងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "លិខិតលេខ ២១៣សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៥) យើងត្រូវពង្រឹងប្រព័ន្ធជាតិ ឬប្រព័ន្ធប្រទេស ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

៦) យើងត្រូវបន្តពិនិត្យ និងបង្កើនលទ្ធភាពក្នុងការគ្របដណ្តប់លើក្រុមប្រជាជនគន្លឹះ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

**ខ្ញុំសូមផ្តល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖**

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពក្នុងពេលខាងមុខ។

២) ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាសេនាធិការបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសិក្សាលើកយោបល់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ពិនិត្យ តាមដាន វាយតម្លៃទៅលើវឌ្ឍនភាពនៃការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជូនកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្តល់អនុសាសន៍ និងសម្រេចអនុវត្ត។

៣) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវខិតខំយកចិត្តទុកដាក់សហការឱ្យបានជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ក្នុងការរៀបចំនីតិវិធីកញ្ចប់ថវិកាជាតិនៅខេត្តដទៃផ្សេងទៀតក្រៅពីរាជធានីនិងខេត្តទាំង៤ និងនៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស។

៤) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវជំរុញ និងសម្របសម្រួលការគ្រប់គ្រងទិន្នន័យនៃការឆ្លើយតបនឹងមេរោគអេដស៍ នៅថ្នាក់រាជធានី ខេត្ត ចំនួនអ្នកផ្ទុកមេរោគអេដស៍ អត្រាឆ្លងថ្មី

អត្រាស្លាប់ ចំនួនអ្នកបោះបង់ការព្យាបាល និងការកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូន។

៥) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេសបន្ថែមលើថវិកាជាតិសម្រាប់និរន្តរភាពកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា រហូតសម្រេចបានជោគជ័យ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ផ្តល់នូវគំនិតល្អៗ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ដើម្បីកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅដោយរលូន និងសម្រេចបានលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជៀសផុតពីជំងឺកូវីដ-១៩គ្រប់ៗគ្នា និងសូមប្រកាសបិទ “**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២១**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***